ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ៥៦ សប្តាហ៍ទី ៤ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

ហោរបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ១៤ រូប ៥៥៤៧

១៣-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧២ ស្ដីពី ការតែងតាំងទីប្រឹក្សារាជរដ្ឋាភិបាល និង ទីប្រឹក្សាបណ្ដាក្រសួងនានា ចំនួន ២៦ រូប ៥៥៤៥

១៣-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧៣ ស្ដីពី ការតម្លើងឋានន្តរស័ក្តិជូន ឯកឧត្តម ម៉ុន ឈរិទ្ធិ ពីវរមន្ត្រីថ្នាក់លេខ ៣ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ៥៥៥២

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ មន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ១៨ រូប ៥៥៥៣

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៧៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ១៦ រូប ៥៥៥៤

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៤ រូប ៥៥៥៥

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោក Shin Eui Cheol តំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ប្រចាំកម្ពុជា ៥៥៥៦

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អង្គការដោះមីនជប៉ុន JMAS ៥៥៥៧

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៣ ស្ដីពី ការតែងតាំងលោក **គេខ ហុតគេខ** ជា ឧកញ៉ា ៥៥៥៨

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៤ ស្ដីពី ការប្ដូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែងជូនមន្ត្រីរាជការ ចំនួន ០៥ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ៥៥៥៩

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម ច័ន្ទ សុនល ៥៥៦០
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៦ រូប ៥៥៦១
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៨ ស្តីពីការតែងតាំង ឯកឧត្តម គីម សំណាង ជា ទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៥៥៦២
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៨៩ ស្តីពី ការតែងតាំង ឯកឧត្តម លី ស៊ីណា ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ពុំទទួលប្រាក់បៀវត្សរ៍ ៥៥៦៣
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩០ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែងជូនមន្ត្រីរាជការ ក្រសួងព័ត៌មាន ចំនួន ០៧ រូប ពីមន្ត្រីក្នុងឋានន្តរស័ក្តិ នាយក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ៥៥៦៤
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩១ ស្តីពី ការតែងតាំងលោក វៃ ម៉េងលីម ជា ឧកញ៉ា ៥៥៦៥
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩២ ស្តីពី ការតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មថ្នាក់ជាតិ (គ.ដ.ន.ជ) ចំនួន ១៣ រូប ៥៥៦៦
១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩៤ ស្តីពី ការតែងតាំង ឯកឧត្តម ផុត សំរេច ជា ទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ដោយមិនទទួលប្រាក់បៀវត្សរ៍ ៥៥៦៨

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១៨-៧-២០១២ -អនុក្រឹត្យលេខ ៨៨០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៥៦៩
១៨-៧-២០១២ -អនុក្រឹត្យលេខ ៨៨១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៥៧០
១៨-៧-២០១២ -អនុក្រឹត្យលេខ ៨៨២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៥៧១
១៨-៧-២០១២ -អនុក្រឹត្យលេខ ៨៨៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៥៧២
១៨-៧-២០១២ -អនុក្រឹត្យលេខ ៨៨៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៥៧៣

២៣-៧-២០១២ -អនុក្រឹត្យលេខ ៨៨៥ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៥៧៤
២៤-៧-២០១២ -អនុក្រឹត្យលេខ ៨៨៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៥៧៥
២៤-៧-២០១២ -អនុក្រឹត្យលេខ ៨៨៧ អនក្រ.តត ស្តីពី ការតែងតាំង និង ដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៥៧៦
២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៨៨ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ និង តែងតាំងមន្ត្រីរាជការ ៥៥៧៧
២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៨៩ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៥៧៩
២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩០ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៥៨០
២៥-៧-២០១២ -អនុក្រឹត្យលេខ ៨៩១ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៥៨១

២.សេចក្តីសម្រេច

២០-៧-២០១២ -សេចក្តីសម្រេចលេខ ២៨ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីកសាងពហុកីឡាដ្ឋានជាតិមរតកតេជោ ជាថ្នូរនឹងដីបឹងពោងពាយ ៥៥៨៣

III.ការងារបណ្ដាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៦-៦-២០១២ -ប្រកាសលេខ ៥៥៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដា ថៃ ភេជីរ (ខេមបូឌា) កូ អិលធីឌី បង្កើតរោងចក្រ ផលិតកេសកាតុង ៥៥៨៥
២៦-៦-២០១២ -ប្រកាសលេខ ៥៥៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រាយ ស្កាយ គីធីអុី អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៥៨៩
២៦-៦-២០១២ -ប្រកាសលេខ ៥៦៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៥៩៣
២៩-៦-២០១២ -ប្រកាសលេខ ៥៨៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុង ជុង ប្លាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៥៩៧
២៩-៦-២០១២ -ប្រកាសលេខ ៥៨៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ែរ៉ូសូហ្វ សាំមីត ហ្វូតវែរ បង្កើតរោងចក្រ ផលិតស្បែកជើង ៥៦០១
២៩-៦-២០១២ -ប្រកាសលេខ ៥៨៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុង សេន ថេកស្តាយ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៦០៥
២៩-៦-២០១២ -ប្រកាសលេខ ៥៨៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រេស៊ីដេន ហ្វូដ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ ផលិតមីកញ្ចប់ ៥៦០៩

២៩-៦-២០១២ -ប្រកាសលេខ ៥៨៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដុង ប៊ូ សាំមីត (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ (ចាក់-ប៉ាក់) ស្រោមដៃ ស្រោមជើង ៥៦១៣

២៩-៦-២០១២ -ប្រកាសលេខ ៥៨៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មេន អ៊ូ ហ្គាមេន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៦១៧

២.ឯកសារក្រសួងពាណិជ្ជកម្ម

០៦-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តា ខឡូ ប្រនីធី ឌីវេឡុបមេន ខូ អិលធីឌី** ៥៦២១

០៦-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៧១ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ថៃ ម៉ូច ឌីវេឡុបមេន** ៥៦២៣

០៦-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីបាច អ៊ិនដាស្ទ្រី ឌីវេឡុបមេន** ៥៦២៥

០៧-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៧៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រស្មី ស៊ូរ៉ាត់** ៥៦២៧

០៧-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើព្រេនធីត សែន ម៉ធើរ អេន អ៊ិនម៉ាយនិងមិន ខនសាល់ធីង** ៥៦២៩

០៧-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៧៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ីល ស្វេសិន ខនសាល់ធីង** ៥៦៣១

០៧-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រតនៈ ស៊ីង គ្រុប** ៥៦៣៣

០៧-៤-២០១១ -លិខិតបញ្ជាក់លេខ ១៩៨៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៉ារីណោហ្ស អ៊ីមផត អិចផត** ៥៦៣៥

០៧-៤-២០១១ -លិខិតបញ្ជាក់លេខ ២០០៤ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ខាសនា ញូ សែន ឆោវ៉ម៉** ៥៦៣៧

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ និង សប្បុរសជន ចំនួន១៨រូប ដែលមានគុណបំណាច់ក្នុងការចូលរួម
ជួយកសាងអភិវឌ្ឍន៍ លើគ្រប់វិស័យ ក្នុងស្រុកគូលែន ខេត្តព្រះវិហារ កន្លងមក

ដូច

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

ឧត្តមសេនីយ៍ទោ **សឿន រឿត** អត្តលេខ ០០១៧២១

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឧត្តមសេនីយ៍ទោ **សុខ សាយ** អត្តលេខ ០០៤១៥៧
២- ឧត្តមសេនីយ៍ត្រី **សាឌុន ណារិទ្ធ** អត្តលេខ ០១១៤៩៦
៣- ឧត្តមសេនីយ៍ត្រី **ឡៀន សោភ័ណវង្ស** អត្តលេខ ០០៩៣៣០

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

១- វរសេនីយ៍ឯក **ស៊ិន ណារិទ្ធ** អត្តលេខ ០៣២២៨៣
២- លោក **ជុំ ពុយ**
៣- លោក **យ៉ាន់ វ៉ាន់**

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១- វរសេនីយ៍ឯក **លឹម ចាន់រិទ្ធី** អត្តលេខ ០២៥១៤២
២- វរសេនីយ៍ទោ **ជុំ សាមេត** អត្តលេខ ០០២០៣១
៣- វរសេនីយ៍ទោ **អ៊ី រតនៈវិសេស** អត្តលេខ ០១១២២៩
៤- វរសេនីយ៍ត្រី **សុខ សំណាង** អត្តលេខ ១៣៧២២៤

ROYAUME DU CAMBODGE • ROYAL • 31 MIN

ព្រះបរមរាជវាំង

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

វរសេនីយ៍ឯក **ចេង សាម៉ីយុទ្ធ** អត្តលេខ ០១៣០៣៧

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- លោក **សាត់ ស៊ី**

២- លោក **គ្រួច ស្រេច**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នសរ.១២០៧.៦៣៩

លេខ:៦៤៨ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

អគ្គលេខា [illegible] ទី១ [illegible] រដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៣២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច

ROYAUME DU CAMBODGE

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សារាជរដ្ឋាភិបាល និងទីប្រឹក្សាបណ្តាក្រសួងនានា ចំនួន ២៦ រូប ដូចខាងក្រោម :

I.-ទីប្រឹក្សារាជរដ្ឋាភិបាល

-ឯកឧត្តម ឈឹម សារិន មានឋានៈស្មើ រដ្ឋមន្ត្រី

-ឯកឧត្តម សុង បូរីណា មានឋានៈស្មើ រដ្ឋមន្ត្រី

II.-ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ឯកឧត្តម សំ សារ៉េត មានឋានៈស្មើ រដ្ឋលេខាធិការ

III.-ទីប្រឹក្សាក្រសួងសាធារណការ និងដឹកជញ្ជូន

-ឯកឧត្តម អ៊ុង វិទ្ធី មានឋានៈស្មើ រដ្ឋលេខាធិការ

IV.-ទីប្រឹក្សាក្រសួងទេសចរណ៍

-ឯកឧត្តម គុំ សុមន្ធា មានឋានៈស្មើ រដ្ឋលេខាធិការ

-ឯកឧត្តម កង សីហា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

V.-ទីប្រឹក្សាក្រសួងការពារជាតិ

-ឯកឧត្តម ខូរ ឈាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

VI.-ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា

-ឯកឧត្តម អ៊ុន សុគន្ធ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

VII.-ទីប្រឹក្សាក្រសួងបរិស្ថាន

-ឯកឧត្តម សាន សុផល មានឋានៈស្មើ អនុរដ្ឋលេខាធិការ

VIII.-ទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-ឯកឧត្តម វ៉ា ប៉ុន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

IX. ទីស្ដីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ឯកឧត្តម ប៊ិន បូកាំ មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម គីម ស៊ីម មានឋានៈស្មើ អនុរដ្ឋលេខាធិការ

X. ទីស្ដីការក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- ឯកឧត្តម ធន់ សារិន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

XI. ទីស្ដីការក្រសួងមហាផ្ទៃ

- ឯកឧត្តម ប្រាំ ស៊ី មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម តាត់ សុហ៊ុម មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម សោភ ស៊ីថុន មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម ហេង សំណាង មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម សៅ សារឹម មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម កៅ លួប្រណៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម ស៊ឹម ស៊ីឃុង មានឋានៈស្មើ អនុរដ្ឋលេខាធិការ

XII. ទីស្ដីការក្រសួងយុត្តិធម៌

- ឯកឧត្តម ស្រី ច័ន្ទនី មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម ព្រឹម សំបូរ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

XIII. ទីស្ដីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- ឯកឧត្តម យឿន យឿត មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម ស៊ូ សារ៉ាត់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

XIV. ទីស្ដីការក្រសួងធម្មការ និងសាសនា

- ឯកឧត្តម ឡាំ ពិញ មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- ឯកឧត្តម ហួត ហ៊ី មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរក.១២០៧.៦៧៥

លេខ: ៦៤៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
... សុខា

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១១ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈពិសេសនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិជូនឯកឧត្តម ម៉ុន សោរិទ្ធិ ពីវរមន្ត្រីថ្នាក់លេខ ៣ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៥៧.១២០៧.៦៧០

[illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ [illegible] ខែកក្កដា ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំនួន១៨រូប
មានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ កន្លងមក

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

១-លោក **ឈី សុខា**	១០-លោក **សាល់ ស៊ីថារិទ្ធិ**
២-លោក **ម៉ើ ផល្លា**	១១-លោក **ម៉ឺន កែម**
៣-លោក **ព្រាប សុរិទ្ធី**	១២-លោក **អ៊ុក តារុណា**
៤-លោកស្រី **ម៉ុំ ច្រណិត**	១៣-លោក **ឡាយ សុមេធី**
៥-លោក **អ៊ុច សុខុម**	១៤-លោកស្រី **ម៉ម សារី**
៦-លោក **មួក ដារិទ្ធ**	១៥-លោក **អ៊ូ ថៃ**
៧-លោក **ឈី ភាយឫទ្ធិ**	១៦-លោក **ឈី មុនីរាថ**
៨-លោក **សោម សុភា**	១៧-លោក **យស់ សុធា**
៩-លោក **យក់ សុផុល**	១៨-លោក **រិន សុខុម**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៦៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]រដ្ឋាភិបាល
[illegible] សុខា

ចរស.១២០៧.៦៩៤

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនិងសប្បុរសជន ចំនួន១៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងបានចូលរួមជួយកសាងអភិវឌ្ឍន៍ភូមិ ឃុំ ក្នុងខេត្តព្រះសីហនុ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍
១-លោក ខួច សីវច័ន្ទ
២-លោកជំទាវ គួច បុប្ផា
៣-លោក ឈិត ស៊ិត

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍
១-លោក ថែន សំបូរ
២-លោក ទី យុត
៣-ព្រះតេជគុណ មុំ សុក្រ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
១-ព្រះតេជគុណ គង់ រ៉ុស
២-លោក ហេង ប៊ុម
៣- លោក ហេង ឆាង
៤-លោក សុខ ឆាង
៥-លោក និត សុជាតិ
៦- លោក ថែន សារឿន
៧-វរនាវីទោ សំ សាមឿន អត្តលេខ ០១១៣៥៩
៨-ព្រះតេជគុណ និន សារ៉ាន

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ និមមិត្ត
១-វរសេនីយ៍ទោ ហេង សាំរុន អត្តលេខ០២០៦១២
២-លោក ឆាង ចន្ទ្រ:

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចម្លងចេញពីច្បាប់ដើម ប.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ... ខែកក្កដា ឆ្នាំ២០១២
... រដ្ឋាភិបាល
... សុខា

៣៩៤.១២០៧.៦៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រកាសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ ចំនួន ០៤រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ជាច្រើន
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ក្នុងខេត្តបាត់ដំបង

ដូច

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តមឧត្តមសេនីយ៍ឯក ស៊ឹម សុផល

២- ឯកឧត្តមឧត្តមសេនីយ៍ទោ ឡាញ់ តី

ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១- លោក ឆិត្យ សារឿន

២- លោក ម៉េង ឡូញ

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

៣៧ល. ១២០៧. ៦៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ២០១២
[illegible]ទីស្តីការគណៈរដ្ឋាភិបាល

[illegible]ជ័យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ឱ្យ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ចំពោះ

លោក Shin Eui Cheol

តំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ប្រចាំកម្ពុជា ដែលមានស្នាដៃល្អ
ក្នុងការធ្វើកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងកម្មវិធីយ៉ាងសកម្មជាមួយក្រសួងអភិវឌ្ឍន៍ជនបទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពសស. ១២០៣. ៦៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៧១ ច.ល
ថតចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

អង្គការដោះមីនជប៉ុន JMAS
ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងសកម្មភាពបោសសំអាតគ្រាប់មីន
និងយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅកម្ពុជា ចាប់ពីឆ្នាំ ២០០២-២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរស. ១២០៧.៦៩៥

លេខៈ ៦៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ៧ ឆ្នាំ២០១២
[illegible]លេខាធិការទីស្តីការគណៈរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក តេង ហុកតេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១២០៧.៦៩០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរង[illegible]រដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្ដូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែងជូនមន្ត្រីរាជការ ០៥រូបទៅក្នុងឋានន្តរស័ក្ដិអនុមន្ត្រី គ្រប់គ្រងរដ្ឋបាល នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម :

ល.រ	គោត្តនាម និងនាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្ដិ និងថ្នាក់	
			ចាស់	ស្នើសុំ
១	ពៅ ស៊ីថា	ប	ពីនាយក្រមការថ្នាក់លេខ១	ទៅអនុមន្ត្រីថ្នាក់លេខ៦
២	លឹម សុថេត	ប	ពីនាយក្រមការថ្នាក់លេខ១	ទៅអនុមន្ត្រីថ្នាក់លេខ៦
៣	ហែម ហឿន	ប	ពីនាយក្រមការថ្នាក់លេខ៦	ទៅអនុមន្ត្រីថ្នាក់លេខ១៤
៤	ហាស់ ប៊ុនធី	ប	ពីនាយក្រមការថ្នាក់លេខ១	ទៅអនុមន្ត្រីថ្នាក់លេខ៦
៥	ចេង ហ៊ាង	ប	ពីនាយក្រមការថ្នាក់លេខ៣	ទៅអនុមន្ត្រីថ្នាក់លេខ៨

មាត្រា ២ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

ហរ៧. ១២០៧. ៦៩១

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខ: ០៥.៥ ច.ស
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការៈ

ចំពោះ

ឯកឧត្តម ច័ន្ទ សុផល

ដែលបានខិតខំបំពេញភារកិច្ច និងមានទំនាក់ទំនងល្អ ជាមួយក្រសួងព្រះបរមរាជវាំង
ក្នុងការបំរើជាតិ សាសនា ព្រះមហាក្សត្រ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាស. ១២០៧. ៦៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២

លេខ: ៦៦៤ ច.ល
ដើម្បីជូនចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២
... រដ្ឋបាល
... សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៦រូប ដែលមានគុណបំណាច់ខ្ពស់ ក្នុងការកសាងព្រះវិហារ កុដិ សាលាធម្មសភា និង ផ្លូវ ស្ថិតនៅក្នុងវត្តសោម ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

- ឯកឧត្តម សាយ សារុន

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១- លោក អេង ឃាង

២- លោក ឈី សុណា

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- លោកជំទាវ ត្រាង សុខ

២- លោក ម៉ូត លីហេង

៣- លោក យេន ហ៊ុង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរស.១២០៧.៦៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២

[illegible] លេខៈ ៦៦៦ ប.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ (?) ខែកក្កដា ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **គីម សំណាង** ជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៣.១២០៧.៦៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ (កក្កដា) ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឈី ស៊ីណា** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ពុំទទួលប្រាក់បៀវត្ស ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរណ.១២០៧.៦៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការក្រសួងព័ត៌មាន ចំនួន ០៧ រូប ពីមន្ត្រីក្នុងឋានន្តរស័ក្តិ នាយក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ៖

ល.រ	គោត្តនាម និង នាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ស្នើសុំ
១	ស៊ុន សាខន	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៦
២	សាន ពុទ្ធារី	ប	ពីនាយក្រមការ ថ្នាក់លេខ ២	ទៅអនុមន្ត្រី ថ្នាក់លេខ ៧
៣	ជឿង យ៉ារ៉េត	ប	ពីនាយក្រមការ ថ្នាក់លេខ ២	ទៅអនុមន្ត្រី ថ្នាក់លេខ ៧
៤	ម៉ក់ វិជ្ជៈ	ប	ពីនាយក្រមការ ថ្នាក់លេខ ៣	ទៅអនុមន្ត្រី ថ្នាក់លេខ ៨
៥	ពាន់ សួរ	ប	ពីនាយក្រមការ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១២
៦	អ៊ុក សាផាន	ប	ពីនាយក្រមការ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១២
៧	ប្រាក់ អេលីរតនា	ស	ពីនាយក្រមការ ថ្នាក់លេខ ៦	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៣.១២០៧.៦៩៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

លេខ ៦៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ... ឆ្នាំ២០១២
... សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក ថៃ ម៉េងលីម

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារល.១២០៧.៦៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

លេខ: ៦៩៧/ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ (គ.ជ.ន.ជ.) ដូចខាងក្រោម៖

១. ឯកឧត្តមបណ្ឌិត **ម៉ែន សុផល**	អគ្គលេខាធិការ	មានឋានៈស្មើរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម **មាន ច័ន្ទវ៉ាន់នី**	អគ្គលេខាធិការរង	មានឋានៈស្មើរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៣. លោកជំទាវ **សួស សុផល**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៤. ឯកឧត្តមបណ្ឌិត **សាររ៉េត ដូរ៉ាមី**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៥. ឯកឧត្តម **ស្រាត់ សម្ដារ៉ា**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៦. ឯកឧត្តម **ចាយ ឫទ្ធិសែន**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៧. ឯកឧត្តមបណ្ឌិត **ខេមមុខ សុជាតិខេមរ៉ូ**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

៨. ឯកឧត្តមបណ្ឌិត **ម៉េង ម៉ុន្នារិទ្ធ**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៩. ឯកឧត្តម **ម៉េង គីមហ៊ី**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
១០. ឯកឧត្តម **ទ័ត្រ ពិសិដ្ឋ**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
១១. ឯកឧត្តម **ឈឹម សុគន្ធ**	អគ្គលេខាធិការរង	មានឋានៈស្មើអគ្គនាយក	បន្ថែមលើមុខងារបច្ចុប្បន្ន
១២. ឯកឧត្តម **យី យ៉ាណារតន៍**	អគ្គលេខាធិការរង	មានឋានៈស្មើអគ្គនាយក	បន្ថែមលើមុខងារបច្ចុប្បន្ន
១៣. ឯកឧត្តម **មិញ សំអឿន**	អគ្គលេខាធិការរង	មានឋានៈស្មើអគ្គនាយក	-បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកត.០៧១២.៦៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

[illegible] លេខៈ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ [illegible] ខែ កក្កដា ឆ្នាំ២០១២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **អ៊ុក សំអេច** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ដោយមិនទទួលប្រាក់បៀវត្សរ៍ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បរទេ.១២០៧.៧០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

លេខៈ ៦៥៩០.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៧០ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះបញ្ញាបទីបោ **ហោ សុខុន** ព្រះចៅអធិការវត្តច្បារអំពៅ ដែលបានបរិច្ចាគបច្ច័យចំនួន ១០.២៥០ ដុល្លារអាមេរិក ក្នុងការជួយកសាងផ្លូវបេតុង០១ខ្សែ កសាងរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ ក្រាលការ៉ូឡាទីធ្លាសាលា សាងសង់បង្គន់អនាម័យ និងជួសជុលដំបូលអគារ ០១ខ្នង ជូនដល់សាលាបឋមសិក្សាច្បារអំពៅទី២ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានផ្តល់ថវិកាសរុបចំនួន ២៥៣.១០៦,៣០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង ០២ជាន់ មាន១៥បន្ទប់ ជូនដល់អនុវិទ្យាល័យវត្តដំបូកខ្ពស់ ក្នុងរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

១-លោក CHRISTIAN des PALLIERES ស្ថាបនិកអង្គការដើម្បីភាពញញឹមនៃកុមារ

២-អ្នកស្រី Marie France BOUCHARD des PALLIERES ស្ថាបនិកអង្គការដើម្បីភាពញញឹមនៃកុមារ

៣-លោក Jean Michel BOUCHARD ប្រធានក្រុមប្រឹក្សាភិបាលអង្គការដើម្បីភាពញញឹមនៃកុមារ

៤-លោក PIN SARAPICH នាយកកម្មវិធីអង្គការដើម្បីភាពញញឹមនៃកុមារ

៥-លោក OUK SOVAN នាយករងកម្មវិធីអង្គការដើម្បីភាពញញឹមនៃកុមារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤៧ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Nakamura Ryuichi ដែលបានផ្តល់ថវិកាចំនួន ៥៩.៩៧៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង មាន៥បន្ទប់ និងអណ្តូងទឹក០១ ជូនដល់អនុវិទ្យាល័យធាយ ស្ថិតនៅភូមិតាសូ ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៥៣ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប តំណាងក្រុមហ៊ុន SUN Group (Japan-Cambodia) ដែលបានផ្តល់ថវិកាសរុបចំនួន ២២.០៤១,១៤ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សាចំនួន០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាបឋមសិក្សាភូមិថ្មី ស្ថិតនៅសង្កាត់ភ្នៀត ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

១-លោក Yamano Yoshio ប្រធានក្រុមហ៊ុន Sun Group (Japan Cambodia)
២-លោក **ស៊ុម ទិសិដ្ឋារ៉ា** ទីប្រឹក្សាក្រុមហ៊ុន Sun Group (Japan Cambodia)

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាសរុបចំនួន ៤៦.៤៣៦ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារបណ្ណាល័យ ព្រមទាំងបំពាក់សម្ភារៈបរិក្ខារគ្រប់គ្រាន់ នៅក្នុងអនុវិទ្យាល័យសម្តេចឪ ស្ថិតនៅក្រុមទី១៤ មណ្ឌល២ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម ៖

១-លោក Steve Glick ប្រធានក្រុមហ៊ុនប្រេងឈេហ្វរ៉ុនអូវើស៊ីអេត្រូលៀម

២-លោក Eric Bergthold ប្រធានអង្គការផេកកម្ពុជា

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៥៥៥ អនក្រ.កក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ទឹន ឆន** អត្តលេខ ០១០៦៥ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៣១២/១៧៥ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការបង្កើតបញ្ជាក្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប ជាអនុប្រធានលេខាធិការដ្ឋាន នៃបញ្ជាក្តិករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ អគ្គនាយករង៖

១- លោក **សាំ ណារិត**

២- លោក **សូ ឃុនវិរៈក្ស**

៣- លោក **សៀង សិទ្ធី**

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធានបញ្ជាក្តិករទូរគមនាគមន៍កម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
ឯកសារ.កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៨៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំង និងដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោកវរសេនីយ៍ទោ **សៅ ចាសនា** អត្តលេខ ០៨២៩៣ ជាជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **សៅ ចាសនា** អត្តលេខ ០៨២៩៣ នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៨៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

